Washington State Health Care Authority

Washington State Department of Social & Health Services
Transforming lives

# សិទ្ធិ និងពេលកំណត់សវនាការរដ្ឋបាល **Washington Apple Health**

## Washington Apple Health Administrative Hearing Rights and Deadlines

អ្នកមានសិទ្ធិប្តឹងសវនាការរដ្ឋបាល បើអ្នកមិនយល់ព្រមជាមួយការសម្រេចរបស់យើង ដែលបានបដិសេធ បញ្ចប់ ឬផ្លាស់ប្តូរការធានារ៉ាប់ Washington Apple Health របស់អ្នក ។

- អ្នកមានពេល 90 ថ្ងៃពីកាលបរិច្ឆេទដែលមាននៅខាងលើសេចក្តីណែនាំនេះក្នុងការស្នើសុំសវនាការ ។ បើអ្នកមិនស្នើសុំសវនាការក្នុងរយៈពេល 90 ថ្ងៃទេ អ្នកអាចបាត់បង់សិទ្ធិប្តឹងសវនាការ ។
- បើអ្នកចង់រក្សាការធានារ៉ាប់របស់អ្នកក្នុងអំឡុងពេលដំណើរការសវនាការ សូមមើល ការបន្តធានារ៉ាប់ក្នុងដំណើរការសវនាការរដ្ឋបាលខាងក្រោម ។
- អ្នកអាចមើលបទបញ្ញត្តិសវនាការក្នុងក្រមរដ្ឋបាលរដ្ឋវ៉ាស៊ីងតោន ជំពូក 182-526 ។
- អ្នកអាចមិនមានសិទ្ធិប្តឹងសវនាការ បើការធានារ៉ាប់របស់អ្នកត្រូវបានបដិសេធ បញ្ចប់ ឬផ្លាស់ប្តូរ ពីព្រោះមានការផ្លាស់ប្តូរច្បាប់រដ្ឋ ឬសហ ព័ន្ធ ហើយវាប៉ះពាល់ដោយស្វ័យប្រវត្តិដល់អ្នកចុះឈ្មោះក្នុងកម្មវិធីដូចៗគ្នា (RCW 74.09.741(3)) ។
- បើអ្នកមានសេចក្តីត្រូវការថែទាំសុខភាពបន្ទាន់ អ្នកអាចស្នើសុំសវនាការរហ័សមួយ ហើយត្រូវតែដាក់ស្នើភស្តុតាងវេជ្ជសាស្ត្រនៃសេចក្តីត្រូវការនោះ ។ ចៅក្រមនឹងសម្រេចចិត្តថាតើអ្នកអាចមានសវនាការរហ័សមួយឬយ៉ាងណា ។ អ្នកអាចមិនទទួលបានសវនាការរហ័ស បើអ្នកទទួលបានការធានារ៉ាប់រងបន្ត ។

យោបល់អប់រំផ្នែកច្បាប់ដែលមានការសម្របសម្រួល និងការបញ្ជូនទៅ អាចជួយអ្នកស្វែងរកជំនួយផ្នែកច្បាប់ដោយឥត គិតថ្លៃ បើអ្នកមានប្រាក់ចំណូលទាប ។ អ្នកអាចដាក់ពាក្យនៅ http://nwjustice.org/clear-online ឬ ៖

- បើអ្នកមានអាយុក្រោម 60 ឆ្នាំ ហៅទូរស័ព្ទមកយោបល់អប់រំផ្នែកច្បាប់ដែលមានការសម្របសម្រួល និងការបញ្ជូនទៅ តាមលេខ 1-888-201-1014 ។
- បើអ្នកមានអាយុលើសពី 60 ឆ្នាំ ហៅទូរស័ព្ទមកយោបល់អប់រំផ្នែកច្បាប់ដែលមានការសម្របសម្រួល និងការបញ្ជូនទៅផ្នែកមនុស្សចាស់ តាមលេខ 1-888-387-7111 ។

ការបន្តធានារ៉ាប់ក្នុងដំណើរការសវនាការ

- អ្នកអាចរក្សាការធានារ៉ាប់រងរបស់អ្នកក្នុងអំឡុងពេលដំណើរការសវនាការ ប្រសិនបើសេចក្តីជូនដំណឹងរបស់អ្នកនិយាយថា យើងនឹងលុបចោល ពន្យារពេល ឬកាត់បន្ថយការធានារ៉ាប់រង Washington Apple Health ឬសេវាដែលបានអនុញ្ញាតពីមុនរបស់អ្នក។
- ដើម្បីរក្សាការធានារ៉ាប់រងរបស់អ្នក អ្នកត្រូវតែស្នើសុំសវនាការ មុនថ្ងៃទី 10 បន្ទាប់ពីយើងបានផ្ញើសេចក្តីជូនដំណឹងនៃចំណាត់ការទៅអ្នក ឬថ្ងៃចុងក្រោយនៃខែនេះមុនពេលចំណាត់ការចាប់មានប្រសិទ្ធភាព ។
- បើអ្នកទទួលការបន្តធានារ៉ាប់រង ឬសេវាកម្ម ហើយចាញ់សវនាការ អ្នកអាចនឹងត្រូវសងប្រាក់មកវិញដល់ 60 ថ្ងៃនៃការបន្តធានារ៉ាប់រង ឬសេវាកម្ម (មើល WAC 182-504-0130) ។
- អ្នកមិនអាចទទួលបានការធានារ៉ាប់រង ពេលដែលកំពុងរង់ចាំសវនាការក្នុងការដេញដោលការបដិសេធនៃសំណុំបែបបទ Washington Apple Health របស់អ្នក ។

សំណើសវនាការរដ្ឋបាល

ដើម្បីស្នើសុំសវនាការរដ្ឋបាល ឬបើអ្នកចង់បានអ្នកបកប្រែ ឬជំនួយផ្សេងៗក្នុងការស្នើសុំសវនាការ សូមធ្វើតាមចំណុចខាងក្រោម ៖

- ទូរស័ព្ទមកមជ្ឈមណ្ឌលសេវាអតិថិជននៃការិយាល័យសេវាសហគមន៍ តាមលេខ 1-877-501-2233 ឬទូរស័ព្ទ ការិយាល័យសេវាកម្មផ្ទះមូលដ្ឋាន និងសហគមន៍របស់អ្នក ។
- ទូរស័ព្ទមកអង្គភាពឯកទេស LTC តាមលេខ 1-855-873-0642 ឬទូរស័ព្ទការិយាល័យរដ្ឋបាលការអភិវឌ្ឍន៍ពិការភាពមូលដ្ឋានរបស់អ្នក ។
- សរសេរសំបុត្រស្នើសុំសវនាការ ឬបំពេញបែបបទស្នើសុំសវនាការរដ្ឋបាល HCA 12-507 (ដែលមាននៅ www.hca.wa.gov/apple-health-client-forms) និង ៖

  ទូរសារមក 1-888-338-7410 ឬ

  ផ្ញើសំបុត្រមក ៖ CSD Customer Service Center PO Box 11699 Tacoma, WA 98411-6699

បើអ្នកមិនដឹងនរណាគួរទាក់ទងទៅកាន់ ទូរស័ព្ទទៅលេខនៅទំព័រទីមួយនៃលិខិតនេះ ។ ពួកយើងនឹងពិនិត្យមើលសំណុំរឿងរបស់អ្នក និងព្យាយាមទាក់ទងអ្នកដើម្បីដោះស្រាយបញ្ហាមុនពេលសវនាការ ។